ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា
លេខ..ន.ក.ជ.ក.ច.ប.ក.ក.ក

ប្រកាស
ស្តីពី
វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២

សម្រេច

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់វិធានប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ តទៅនេះហៅថា

"ធនាគារភ្នាក់ងារ" ដែលទទួលប្រតិស្រុតពីគណៈកម្មការមូលបត្រកម្ពុជា ឱ្យធ្វើសកម្មភាពជាត់ទាត់ ឬទូទាត់សាច់ប្រាក់សម្រាប់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ ដែលមានគណនីទូទាត់សាច់ប្រាក់ជាមួយធនាគារភ្នាក់ងារ។

ប្រការ ២.-

ធនាគារភ្នាក់ងារត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដូចខាងក្រោមនេះ៖

១. ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី គោលនយោបាយ នីតិវិធី និងដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាម ហើយតែងតាំងបុគ្គលិកមានចំណេះដឹងដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវឱ្យទទួលបន្ទុកការងារនេះ។ ការត្រួតពិនិត្យនេះត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ហើយត្រូវបានវាយតម្លៃឡើងវិញប្រចាំគ្រាអំពីប្រសិទ្ធភាពភាពគ្រប់គ្រាន់ និងតម្រូវការក្នុងការកែលម្អ។

២. ត្រូវធានាឱ្យមាន ៖

ក. ការញែកឱ្យដាច់ពីគ្នារវាងដំណើរការទូទាត់សម្រាប់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រ និងដំណើរការទូទាត់សម្រាប់សកម្មភាពប្រតិបត្តិការធម្មតា ដែលចែងក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ខ. ការញែកឱ្យដាច់ពីគ្នារវាងគណនីអតិថិជនរបស់ក្រុមហ៊ុនមូលបត្រសម្រាប់ទូទាត់ប្រតិបត្តិការក្នុងទីផ្សារមូលបត្រកម្ពុជា និងគណនីប្រាក់បញ្ញើអតិថិជនធម្មតា។ គណនីទូទាត់របស់ក្រុមហ៊ុនមូលបត្រដែលមានឬគ្មានសិទ្ធិអំណាចជាអ្នកធានាទិញ ឬជួញដូរមូលបត្រ ក៏ត្រូវញែកឱ្យដាច់ពីគ្នា ដើម្បីចៀសវាងការលាយឡំគ្នារវាងសាច់ប្រាក់របស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ និងប្រាក់បញ្ញើរបស់អតិថិជនធម្មតា។

គ. ដំណើរការទាំងអស់ដែលពាក់ព័ន្ធសម្រាប់ចាត់ចែង និងទូទាត់ប្រតិបត្តិការទិញ-លក់មូលបត្រត្រូវមានឯកសារយោងតាមលំនាំសវនកម្ម (Audit trail process) ដែលសមស្រប និងមានប្រសិទ្ធភាព។ ប្រសិទ្ធភាពនៃលំនាំសវនកម្មត្រូវបានធ្វើតេស្ត និងវាយតម្លៃឡើងវិញជាប្រចាំ។ ឯកសារនៃដំណើរការនិងនីតិវិធីទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងរក្សាទុក។ ឯកសារយោងតាមលំនាំសវនកម្មត្រូវបានការពារ និងរក្សាទុកសម្រាប់រយៈពេលយ៉ាងតិច ៥ឆ្នាំ (ប្រាំឆ្នាំ) និងត្រូវផ្តល់ឱ្យស្នងការគណនីឯករាជ្យ គណៈកម្មការមូលបត្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា តាមសំណើ។

ប្រការ ៣.-

១. ធនាគារភ្នាក់ងារមិនត្រូវផ្តល់ឥណទានវិបារូបន៍ ឬឥណទានផ្សេងទៀតដល់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រក្នុងការប្រើប្រាស់សម្រាប់គោលបំណងទូទាត់ប្រតិបត្តិការទិញ-លក់ក្នុងទីផ្សារមូលបត្រកម្ពុជា។

២. ដើម្បីធានានូវការញែកឱ្យដាច់ពីគ្នារវាងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជន ធនាគារភ្នាក់ងារមិនត្រូវប្រើប្រាស់សមតុល្យទឹកប្រាក់របស់អតិថិជននៃក្រុមហ៊ុនមូលបត្រជាប្រភពទុនសម្រាប់សកម្មភាពប្រតិបត្តិការធម្មតារបស់ធនាគារភ្នាក់ងារទេ។

៣. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រ(ទ្រព្យអកម្ម) ត្រូវដកចេញពីភាគយក និងថ្លឹង១០០% (មួយរយភាគរយ) ក្នុងខ្ជង់ភាគបែង។

៤. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

ប្រការ ៤.-

១. គណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារមិនតម្រូវឱ្យតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជាទេ។

២. ក្នុងការគណនាអនុបាតសន្ទនីយភាព សមតុល្យគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ក្រុមហ៊ុនមូលបត្រនៅធនាគារភ្នាក់ងារ ត្រូវដកចេញពីភាគយក និងថ្លឹង១០០% (មួយរយភាគរយ) ក្នុងខ្ជង់ភាគបែង។

ប្រការ ៥.-

១. ដោយពិនិត្យលើហានិភ័យនៃការបង្ហាក់ដល់ដំណើរការទូទាត់និងជាត់ទាត់ជាទូទៅ ដែលបណ្តាលមកពីធនាគារភ្នាក់ងារខកខានក្នុងការទូទាត់ ឬជាត់ទាត់សាច់ប្រាក់ ធនាគារភ្នាក់ងារត្រូវបង្កើតផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មសមស្រប ដោយមានដំណោះស្រាយបែកអាប់ (Back-up) គ្រប់គ្រាន់។

២. ការធ្វើផែនការយថាភាពនិងនិរន្តរភាពអាជីវកម្មនោះ ត្រូវពិចារណាទាំងលើការខកខាន ឬការបង្ហាក់ដែលផ្តើមចេញពីធនាគារភ្នាក់ងារ និងពីកត្តាខាងក្រៅ។

៣. ត្រូវរៀបចំចងក្រងជាឯកសារ និងធ្វើតេស្តជាប្រចាំ ដើម្បីវាយតម្លៃឡើងវិញពីប្រសិទ្ធភាពនៃការធ្វើផែនការ នីតិវិធីនិងដំណើរការយថាភាពនិងនិរន្តរភាពអាជីវកម្ម។ ឯកសារទាំងនេះត្រូវបានរក្សាទុកជាកាលប្បវត្តិនិងធ្វើបច្ចុប្បន្នកម្ម។

៤. សវនកម្មផ្ទៃក្នុងរបស់ធនាគារភ្នាក់ងារ ត្រូវធ្វើការវាយតម្លៃដោយឯករាជ្យនិងជាប្រចាំលើផែនការ នីតិវិធីនិងដំណើរការបែកអាប់ (Back-up) ហើយគណៈគ្រប់គ្រងធនាគារភ្នាក់ងារត្រូវពិចារណានិងដោះស្រាយ ជាបន្ទាន់តាមអនុសាសន៍របស់សវនករផ្ទៃក្នុង។

ប្រការ ៦.-

ធនាគារភ្នាក់ងារដែលមិនអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡាគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១២

ហ៊ុន សែន

កន្លែងទទួល

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ចម្លងជូន

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA
Number B7_012_185 ProrkOr.

Unofficial translation

PRAKAS

ON

PRUDENTIAL RULES AND RISK MANAGEMENT REQUIREMENTS APPLICABLE FOR BANKING AND FINANCIAL INSTITUTIONS ACTING AS CASH SETTLEMENT AGENTS RELATED TO SECURITIES

*****

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006 promulgating the Law on the Amendment of article 14 and 57 of Organization and Function of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0412/337 of April 17, 2012 on the reappointment of **His Excellency Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to Prkas No B1-010-194 Prokor dated 26 November 2010 on the amendment of Article 3, Article 4, Article 5, Article 12 and Article 13 of Prakas on Organization Structure of the National Bank of Cambodia and all departments of the National Bank of Cambodia;
- Pursuant to the recommendation made by National Bank of Cambodia Management meeting on 17 August 2012.

Decides:

Article 1.

The present Prakas aims at setting forth the prudential rules and risk management requirement applicable to the commercial banks acting as Cash Settlement Agent related to securities, hereafter called "Agent bank" which authorized by Securities Exchange Commission of Cambodia (SECC) for the purposes of settling the cash transactions generated by transactions performed by Securities Firms' customers holding cash settlement accounts with Agent bank.

Article 2.

Agent bank shall set up the internal control system as follow:

1. The Internal Controls and Compliance Control policies, procedures and processes shall be clearly defined and duly trained and knowledgeable individuals in charge of the performance of such controls shall be designated within the organization. Such Internal and Compliance Controls shall be considered as part of the overall Internal Control System of the Banks and shall be periodically reassessed in light of their effectiveness, adequacy and need for upgrading.

2. The Agent bank shall notably ensure for:
   a) Separate settlement processes for the purposes of settling transactions performed in the Stock Exchange Market and the ones carried out to support regular banking activities as foreseen by the Law on Banking and Financial Institutions;
   b) Segregation of accounts held with customers of securities firms in order to settle securities transactions performed with the Cambodian Stock Exchange and the ones held by regular depositors. Settlement accounts held by Securities Firms with or without underwriting or proprietary trading authorities shall be segregated as well in order to prevent from any possible commingling with securities customers' and regular depositors' moneys;
   c) All the processes involved for the purposes of organizing and settling Stock Exchange transactions shall be supported by appropriate and effective audit trail processes. Effectiveness of such audit trail processes shall be periodically tested and reassessed. The corresponding documentation of processes and procedures shall be subsequently updated and maintained; audit trail records shall be safeguarded and stored for a minimum of 5 years (five years) and provided, upon request, to External Auditors, SECC and NBC.

Article 3.

1. The Agent banks are prohibited from issuing overdraft or credit facilities to securities firms' customers for the purposes of settling their transactions with the Cambodian Stock Exchange.
2. To ensure for proper segregation of securities cash settlement accounts held by securities firms' customers with the Agent banks, such banks are prohibited from using such balances held as a regular funding source for the performance of their regular banking activities.
3. For the purposes of liquidity ratio calculation, such "Securities Firms' Customers-accounts (liabilities)" shall be deducted from numerator and weighted 100% in denominator.
4. Securities Firms' Customers-Accounts at Agent banks are not subject to reserve requirements to be maintained with the National Bank of Cambodia.

Article 4.

1. Cash Settlement Account-Balances maintained by Securities Firms with the Agent bank shall not be subject to reserve requirements to be maintained with the National Bank of Cambodia.

2. For the purposes of liquidity ratio calculation, Cash Settlement Account-Balances maintained by Securities Firms (liabilities) with the bank shall be deducted from numerator and weighted 100% in denominator.

Article 5.

1. Given the risk of disruption for the overall cash clearing and settlement processes represented by any failure originating with any of the Agent banks, the banks shall establish appropriate business contingency and continuity planning with adequate back-up solutions.
2. Such contingency and business continuity planning shall be considered in light of both, failures or disruptions originating within the Agent banks and external disruptions or failures.
3. Contingency and business continuity planning, procedures and processes shall be documented and periodically tested for reassessment of the effectiveness. Documentation shall be maintained up-to-date and results of testing performed shall be documented.
4. Internal audit of the bank shall perform periodic and independent assessments of planning; procedures and back-up processes, and audit recommendations shall be immediately considered by Agent bank management and addressed.

Article 6.

Agent banks which violate the provision of this Prakas may give rise to disciplinary sanction as set forth in Article 52, 53 and 54 of the Law on Banking and Financial Institutions.

Article 7.

The General Secretariat, the General Directorate of Supervision, the Technical General Directorate, the General Inspection, General Cashier, all departments of the National Bank of Cambodia, all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

Article 8.

This Prakas shall have effect from the signing date.

Phnom Penh, 31 December 2012

Governor

Signed and sealed: **Chea Chanto**

Cc: - All members of the Board of Directors
- The parties concerned as stated in article 7
- File
- CM " for info"
- Administration Department of CM
" for publication in the National Gazette"